ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០២៣០ អបស/ឱអបស

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៨

# ប្រកាស

## ស្តីពី

## ការកែសម្រួលប្រកាសលេខ ៥៧០ អបស/ឱអបស ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៩៨ របស់ក្រសួងសុខាភិបាល ស្តីពី បែបបទ និង លក្ខខណ្ឌ ក្នុងការសុំបើក ឬបិទ ឬប្តូរទីតាំង នៃអគារលក់ឱសថបុរាណ

## រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ កញ្ញា ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញ ព្រះរាជក្រម ជស/រកម/០៦៩៦/០២ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ ស្តីពី ការគ្រប់គ្រងឱសថ
- បានឃើញ ព្រះរាជក្រម នស/រកម/១២០៧/០៣៧ ចុះថ្ងៃទី ២៨ ធ្នូ ២០០៧ ប្រកាសឱ្យប្រើច្បាប់ ស្តីពី វិសោធនកម្ម ច្បាប់ ស្តីពី ការគ្រប់គ្រងឱសថ
- បានឃើញ អនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី ២២ តុលា ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញ អនុក្រឹត្យលេខ ២៣ អនក្រ-បក ចុះថ្ងៃទី ២៨ មេសា ១៩៩៨ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីផលិតកម្ម អាហរណ៍ និហរណកម្ម និងពាណិជ្ជកម្មឱសថបុរាណ សំរាប់វិស័យសុខាភិបាល
- បានឃើញ ប្រកាសលេខ ៥៧០ អបស/ឱអបស ចុះថ្ងៃទី ៦ តុលា ឆ្នាំ ១៩៩៨ របស់ក្រសួងសុខាភិបាល ស្តីពី បែបបទ និង លក្ខខណ្ឌ ក្នុងការសុំបើក ឬបិទ ឬប្តូរទីតាំង នៃអគារលក់ឱសថបុរាណ
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល ។

## ស ម្រេ ច

ប្រការ១ : ខ្លឹមសារប្រកាសលេខ ៥៧០ អបស/ឱអបស ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៩៨ របស់ក្រសួងសុខាភិបាល ត្រូវបានកែសម្រួលដូចខាងក្រោម ។

ប្រការ២ : ការបើក ការបិទ និងការប្តូរទីតាំង នៃអគារលក់ឱសថបុរាណ អាចប្រព្រឹត្តទៅបានលុះត្រាតែបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាល ។

457

**ប្រការ៣ :** ការបើកសាខាអគារលក់ឱសថបូរាណនៅក្នុងរាជធានី និង តាមបណ្តាខេត្តត្រូវហាមឃាត់ជាដាច់ខាត ។

**ប្រការ៤ :** គ្រូថ្នាំបូរាណទាំងពីរភេទមានសិទ្ធិសុំបើក អគារលក់ឱសថបូរាណបាន ត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម :

-មានសញ្ជាតិខ្មែរ

-មានវិញ្ញាបនប័ត្រគ្រូថ្នាំបូរាណដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល

-មិនជាប់ក្នុងបញ្ជីថ្កោលទោសពីទោសឧក្រិដ្ឋណាមួយ

-មានសុខភាពគ្រប់គ្រាន់អាចបំពេញការងារបាន ។

**ប្រការ៥ :** សំណុំលិខិតសុំបើក អគារលក់ឱសថបូរាណមាន :

| | |
|---|---|
| -ពាក្យសុំបើក "មានតំរូ" | ១ ច្បាប់ |
| -វិញ្ញាបនប័ត្រគ្រូថ្នាំបូរាណ ទទួលស្គាល់ដោយក្រសួងសុខាភិបាល | ១ ច្បាប់ |
| -ប្រវត្តិរូបសង្ខេបរបស់សាមីជន "មានតំរូ" | ១ ច្បាប់ |
| -វិញ្ញាបនប័ត្រសុខភាពចេញដោយមន្ទីរសុខាភិបាលរាជធានី-ខេត្ត | ១ ច្បាប់ |
| -លិខិតថ្កោលទោស ដែលនៅមានសុពលភាព ចេញដោយក្រសួងយុត្តិធម៌ | ១ ច្បាប់ |
| -គំនូសបំព្រួញទីតាំង ដោយមានចំណារឯកភាពពីសង្កាត់ឬឃុំ | ១ ច្បាប់ |
| -រូបថតបង្ហាញអគារ ( ថតចំពីមុខ ខាងក្នុង និងឃ្លាំង ) យ៉ាងតិច | ៣ សន្លឹក |
| -រូបថតសាមីជន ៤ x ៦ សម | ៣ សន្លឹក |

**ប្រការ៦ :** ការសុំប្តូរទីតាំងនៃអគារលក់ឱសថបូរាណ ត្រូវបំពេញសំណុំលិខិតដូចខាងក្រោម :

| | |
|---|---|
| -ពាក្យសុំប្តូរទីតាំង "មានតំរូ" | ១ ច្បាប់ |
| -លិខិតអនុញ្ញាតបើក "ច្បាប់ដើម" | ១ ច្បាប់ |
| -គំនូសបំព្រួញទីតាំង ដោយមានចំណារឯកភាពពីសង្កាត់ឬឃុំ | ១ ច្បាប់ |
| -រូបថតបង្ហាញអគារថ្មី ( ថតចំពីមុខ ខាងក្នុង និងឃ្លាំង ) យ៉ាងតិច | ៣ សន្លឹក |
| -រូបថតសាមីជន ៤ x ៦ សម | ៣ សន្លឹក |

**ប្រការ៧ :** ការសុំផ្លាស់ប្តូរគ្រូថ្នាំបូរាណដែលទទួលខុសត្រូវអគារលក់ឱសថបូរាណ ត្រូវបំពេញសំណុំលិខិតរបស់គ្រូថ្នាំបូរាណអ្នកជំនួសដូចខាងក្រោម :

| | |
|---|---|
| -ពាក្យសុំផ្លាស់ប្តូរ "មានតំរូ" | ១ ច្បាប់ |
| -វិញ្ញាបនប័ត្រគ្រូថ្នាំបូរាណ ទទួលស្គាល់ដោយក្រសួងសុខាភិបាល | ១ ច្បាប់ |
| -ប្រវត្តិរូបសង្ខេបរបស់សាមីជន "មានតំរូ" | ១ ច្បាប់ |
| -វិញ្ញាបនប័ត្រសុខភាពចេញដោយមន្ទីរសុខាភិបាលរាជធានី-ខេត្ត | ១ ច្បាប់ |

-លិខិតថ្កោលទោស ដែលនៅមានសុពលភាព ចេញដោយក្រសួងយុត្តិធម៌ ១ ច្បាប់

-គំនូសបំព្រួញទីតាំង ដោយមានចំណារឯកភាពពីសង្កាត់ឬឃុំ ១ ច្បាប់

-រូបថតបង្ហាញអគារ ( ថតចំពីមុខ ខាងក្នុង និងឃ្លាំង ) យ៉ាងតិច ៣ សន្លឹក

-រូបថតសាម៉ីជន ៤ x ៦ សម ៣ សន្លឹក

ប្រការ៨ : ក្រសួងសុខាភិបាល នឹងផ្តល់ចម្លើយ អំពីការសុំបើក ឬការសុំប្តូរទីតាំងអគារលក់ឱសថបុរាណ ឬការសុំផ្លាស់ប្តូរគ្រូថ្នាំបុរាណ ដល់សាម៉ីជនយ៉ាងយឺតបំផុត ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលសំណុំលិខិតគ្រប់គ្រាន់និងត្រឹមត្រូវ នៅនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង តាមរយៈមន្ទីរសុខាភិបាលរាជធានី-ខេត្ត ។

ប្រការ៩ : គ្រូថ្នាំបុរាណមួយរូប មានសិទ្ធិដាក់ពាក្យសុំបើកអគារលក់ឱសថបុរាណបានតែមួយកន្លែង និងមិនអាចប្រកបវិជ្ជាជីវៈសុខាភិបាលផ្សេងទៀតឡើយ ។

ប្រការ១០ : ក្រោយពីបានទទួលលិខិតអនុញ្ញាត ស្តីពី ការបើកអគារលក់ឱសថបុរាណ ពីក្រសួងសុខាភិបាល សាម៉ីជនត្រូវបើកទ្វារបំរើសាធារណជនយ៉ាងយឺតបំផុត ៣ខែ ។ ផុតកំណត់ខាងលើ បើអគារលក់ឱសថបុរាណគ្មានដំណើរការទេនោះ លិខិតអនុញ្ញាតត្រូវទុកជាមោឃៈដោយស្វ័យប្រវត្តិ ។ ក្នុងករណីមានមូលហេតុសមស្របតាមការវាយតម្លៃរបស់មន្ទីរសុខាភិបាលរាជធានី-ខេត្ត រយៈកាលកំណត់ខាងលើអាចពន្យារបាន ៣ខែ ទៀតហើយបានតែមួយដងគត់ តាមសំណើរបស់សាម៉ីជន ។

ប្រការ១១ : អំពីការរៀបចំអគារលក់ឱសថបុរាណ :

អគារលក់ឱសថបុរាណ ត្រូវដាច់ចេញពីកន្លែងស្នាក់នៅ មានអនាម័យស្អាតបាត ទាំងខាងក្នុង ទាំងខាងក្រៅ និងមានការរៀបចំសមស្របតាមការកំណត់ដូចខាងក្រោម :

១-មានផ្ទៃក្រឡាអាជីវកម្មយ៉ាងតិច ១៦ ម$^{២}$

២-មានស្លាកសញ្ញាអគារលក់ឱសថបុរាណ ដែលមានផ្ទៃពណ៌ក្រហម អក្សរពណ៌លឿង ទំហំយ៉ាងតូច ០.៤ x ២.០ម

៣-ហាមផ្សព្វផ្សាយពាណិជ្ជកម្មតាមគ្រប់រូបភាពលើស្លាកសញ្ញាអគារលក់ឱសថបុរាណ

៤-មានទូរបញ្ឈរ ទូរតាំង និងកំណល់គ្រប់គ្រាន់សំរាប់តាំងលក់

៥-មានឃ្លាំងស្តុកឱសថបុរាណត្រឹមត្រូវ

៦-បន្ទប់ផ្សំឱសថប្រសិនបើមាន ត្រូវរៀបចំឱ្យបានសមស្របតាមបច្ចេកទេសឱសថសាស្ត្រ ។

**ប្រការ១២ :** អគារលក់ឱសថបុរាណអាចតាំងលក់នូវប្រភេទថ្នាំបុរាណដូចខាងក្រោម :

១-រុក្ខជាតិ សត្វ ឬសិលាជាតិគ្រប់ប្រភេទ ដែលមិនទាន់កែច្នៃ ឬបានកែច្នៃតាមវិធីសាស្ត្រសាមញ្ញ ដែលមានគុណភាពបង្ការ ឬព្យាបាលជម្ងឺ លើកលែងតែរុក្ខជាតិពុលដែលមានក្នុងបញ្ជីហាមឃាត់របស់ក្រសួងសុខាភិបាល

២-ផលិតផលឱសថបុរាណ ដែលមានលេខទិដ្ឋាការ-បញ្ជិការួចហើយពីក្រសួងសុខាភិបាល ។

**ប្រការ១៣ :** អគារលក់ឱសថបុរាណមានសិទ្ធិដូចតទៅ :

១-ពិនិត្យព្យាបាលជម្ងឺ ដោយប្រើឱសថបុរាណ

២-លក់រាយនូវផលិតផលដូចមានចែងក្នុងប្រការ ១២

៣-ផ្សំឱសថបុរាណមួយចំនួនតាមក្បួនវេជ្ជសាស្ត្របុរាណក្នុងទ្រង់ទ្រាយតូច គឺផ្សំភ្លាម១ជូនអ្នកជម្ងឺ និងលក់ផ្ទាល់ក្នុងអគារលក់របស់ខ្លួន

៤-ការផលិតឱសថបុរាណក្នុងលក្ខណៈ ទ្រង់ទ្រាយមធ្យម ឬធំ គឺការលក់ដុំ និង ចែកចាយដល់អគារលក់ឱសថបុរាណនានា ត្រូវមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

**ប្រការ ១៤ :** ត្រូវហាមឃាត់ :

១-ការលក់ឱសថបុរាណក្លែងក្លាយ គ្មានគុណភាព

២-ការលក់ឱសថបុរាណលាយឡំជាមួយឱសថសម័យ

៣-ការលក់ឱសថបុរាណដែលបង្កគ្រោះថ្នាក់ មានក្នុងបញ្ជីហាមឃាត់របស់ក្រសួងសុខាភិបាល

៤-ការផលិតឱសថបុរាណដោយយកវត្ថុធាតុគីមីលាយផ្សំជាមួយ

៥-ការប្រកបអាជីវកម្មផ្សេងទៀតក្នុងអគារលក់ឱសថបុរាណ

៦-ការផ្សព្វផ្សាយពាណិជ្ជកម្មឱសថបុរាណដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល

៧-ការព្យាបាលជម្ងឺដោយប្រើឱសថសម័យ ឬវេជ្ជសាស្ត្រសម័យ ។

**ប្រការ១៥ :** ក្នុងអគារលក់ឱសថបុរាណ ត្រូវមានវត្តមានរបស់គ្រូថ្នាំបុរាណ ដើម្បីគ្រប់គ្រងសកម្មភាពអាជីវកម្មឱសថបុរាណ និងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។ ក្នុងករណីអវត្តមានគ្រូថ្នាំបុរាណទទួលខុសត្រូវ ត្រូវមានគ្រូថ្នាំបុរាណមួយរូបទៀតជំនួសដោយមានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

**ប្រការ១៦ :** ក្រសួងសុខាភិបាលនឹងដកហូតវិញនូវច្បាប់អនុញ្ញាតបើក ឬ ប្តូរទីតាំង ឬ ប្តូរគ្រូថ្នាំបុរាណទទួលខុសត្រូវនៃអគារលក់ឱសថបុរាណ ក្នុងករណីពិនិត្យឃើញថា :

១-សាម៉ីជនអនុវត្តមិនត្រឹមត្រូវតាមប្រការ ១១-១២-១៣-១៤-១៥

២-សាម៉ីជនជាប់ក្នុងបញ្ជីចោទប្រកាន់ពីទោសឧក្រិដ្ឋណាមួយ ។ ꕥ

<u>ប្រការ១៧</u> : ខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋានក្រសួងសុខាភិបាល អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និង គ្រឿងសំអាង និងមន្ទីរសុខាភិបាលរាជធានី-ខេត្ត មានភារកិច្ចអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀងខ្លួន ។

<u>ប្រការ១៨</u> : ខ្លឹមសារប្រកាសលេខ ៥៧០ អបស/ឱអបស ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៩៨ របស់ក្រសួងសុខាភិបាល ព្រមទាំងបទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

<u>ប្រការ១៩</u> : ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

<u>ចម្លងជូន</u> :

-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងយុត្តិធម៌
-ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច
-សាលាក្រុងភ្នំពេញ "ដើម្បីផ្សាយជាព័ត៌មាន និងសហការ"
-អគ្គាធិការដ្ឋានក្រសួងសុខាភិបាល
-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-លេខាធិការដ្ឋានគណៈកម្មការលុបបំបាត់ឱសថក្លែងក្លាយរាជធានី-ខេត្ត
-មន្ទីរសុខាភិបាលរាជធានី-ខេត្ត
"ដើម្បីអនុវត្ត"
-ឯកសារ
-កាលប្បវត្តិ

ម៉ម_ប៊ុនហេង